ខុមហ្វ្រែល COMFREL

# របៀបបោះឆ្នោតជ្រើសរើសស្ត្រី




កែសំរួល និងបោះពុម្ពលើកទី២
ដោយគណៈកម្មាធិការខុមហ្វ្រែល
ខែឧសភា ឆ្នាំ២០០៨

# តួអង្គសំខាន់ៗ :



សិលា ជានិស្សិត



គង្គារ ជានិស្សិត



នីកា ជានិស្សិត



សម្បត្តិ ជាតំណាងអង្គការខុមប្រែល



រតនៈ ជាស្ត្រីសកម្មក្នុងឃុំ



តាសួន ជាព្រឹទ្ធាចារ្យយល់ដឹងច្រើនក្នុងឃុំ



មីងសុភាព ជាស្ត្រីសកម្មក្នុងឃុំ



ចំរើន ជាកសិករ



មីងនាគ ជាសិប្បករ



ពូជំនោរ ជាសិប្បករ

# សង្ខេបរឿង:

**តើត្រូវធ្វើយ៉ាងម៉េច! ទើបបោះឆ្នោតឱ្យបានជាប់ស្ត្រី?**

អ្នកបោះឆ្នោត ត្រូវសង្កេត តាមដាន ពិនិត្យមើល ដូចតទៅ :

- ដំបូងត្រូវពិនិត្យមើលបញ្ជីបេក្ខជន បេក្ខនារីឈរឈ្មោះនៃគណបក្សនយោបាយ ថាតើ មានដាក់បេក្ខនារី**ឆ្លាស់គ្នា**ជាមួយបេក្ខជនជាបុរស នៅលេខរៀងខាងលើឬទេ? ព្រោះអ្នក ដែលនៅលេខរៀងខាងលើអាចមានលទ្ធភាពជាប់ច្រើន ។
- អាចទៅមើលបញ្ជីបេក្ខជនឈរឈ្មោះដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បិទផ្សាយទៅតាមមណ្ឌលបោះឆ្នោតខេត្តក្រុងក្នុងរយៈពេលយ៉ាងតិច ៣០ថ្ងៃ មុនថ្ងៃបោះឆ្នោត ពីព្រោះក្នុងសន្លឹកឆ្នោតមិនមានដាក់បង្ហាញបញ្ជីបេក្ខជនឈរឈ្មោះឡើយ ។
- បន្ទាប់មក ! យើងក៏គួរពិនិត្យផងដែរ អំពីគោលនយោបាយគណបក្ស ថាតើមាននិន្នាការទៅរកលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស មានគំនិតអធ្យាស្រ័យ ពហុនិយម ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងមានគោលនយោបាយលើកកំពស់សិទ្ធិស្ត្រី សមភាពយេនឌ័រ ឬទេ? ហើយអ្នកដឹកនាំគណបក្សនោះជាអ្នកណា?
- បេក្ខជនស្ត្រី-បុរសមិនធ្លាប់រកស៊ីខុសច្បាប់ បន្លំ ឆបោក ទារប្រាក់ពីប្រជាពលរដ្ឋ ឬប្រព្រឹត្តិអំពើហិង្សាក្នុងគ្រួសារ ឬរំលោភសិទ្ធិអ្នកដទៃ ឬមានបញ្ហាផ្សេងៗទៀតនោះទេ!
- ឧទាហរណ៍ថា យើងទុកចិត្តបេក្ខនារី "ក" យើងត្រូវបោះឆ្នោតឱ្យគណបក្ស ដែលបេក្ខនារី "ក" នោះឈរឈ្មោះ !

*បោះឆ្នោតគាំទ្រស្ត្រី ដើម្បីឲ្យស្ត្រីមានឱកាសចូលរួមធ្វើសេចក្តីសំរេចដើម្បីដឹកនាំ និងអភិវឌ្ឍប្រទេសជាតិរបស់យើង និងដើម្បីភាពរុងរឿងទាំងអស់គ្នា!*

# មូលហេតុត្រូវការស្ត្រីចូលរួមក្នុងនយោបាយ សង្គម និងសេដ្ឋកិច្ច

មាត្រា ៣៤ និង ៣៥ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត" និង "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ" ។





តើត្រូវធ្វើយ៉ាងណា ដើម្បីឱ្យបុរស
និងស្ត្រី អាចឈរឈ្មោះឱ្យគេបោះ
ឆ្នោត ដោយស្មើភាពគ្នាតាមស្មារតី
រដ្ឋធម្មនុញ្ញ ?




មែនហើយ! ស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាក្នុងការ
ទទួលបាននូវឱកាស និងផលប្រយោជន៍ពីជីវភាព
នយោបាយ សេដ្ឋកិច្ច សង្គម។



ការចូលរួមរបស់ស្ត្រី និងបុរស ដោយស្មើភាពគ្នា ជាការត្រឹមត្រូវ ព្រោះថាស្ត្រីមានចំនួនច្រើនជាងបុរស ហើយចំនួនស្ត្រី ៨២%សកម្មក្នុងវិស័យសេដ្ឋកិច្ច ។





ម្យ៉ាងទៀតប្រវត្តិសាស្ត្រខ្មែរពីមុន ដូចជា ព្រះនាងសោមា និង ព្រះនាងឥន្ទ្រទេវី ធ្លាប់មានភាពល្បីល្បាញក្នុងការដឹកនាំប្រទេស ។ មិនតែប៉ុណ្ណោះ វប្បធម៌ខ្មែរពីដើមធ្លាប់បានផ្តល់តួនាទីក្នុងភាពជាអ្នកដឹកនាំ និងការគោរពចំពោះស្ត្រី ព្រោះស្ត្រីជាដៃគូអភិវឌ្ឍន៍ដ៏ស័ក្តិសម ជាមង្គល ជាសិរីដ៏ឧត្តមក្នុងក្រុមគ្រួសារ និងក្នុងសង្គម ក៏ដូចនៅក្នុងឃុំ-សង្កាត់ ប្រទេសជាតិយើងដែរ ។

# មីងសុភាព និងការឈរឈ្មោះជាបេក្ខជន

បោះឆ្នោតឱ្យស្ត្រី! បោះឆ្នោតឱ្យស្ត្រី! បោះឆ្នោតឱ្យស្ត្រី!






រឿងនេះវាពិតជាសំខាន់ណាស់ ខ្ញុំមានការចាប់អារម្មណ៍ខ្លាំងមែនទែន! ប៉ុន្តែ តើត្រូវធ្វើយ៉ាងម៉េច! ទើបបោះឆ្នោតឱ្យ បានជាប់ស្ត្រីទៅហ្ន៎?!



មែនហើយឪវា! រឿងនេះខ្ញុំកំពុងតែគិត ព្រោះការបោះឆ្នោតជិតមកដល់ក្នុង ពេលឆាប់ៗនេះហើយ ហើយយើងចង់បានស្ត្រីចំនួនច្រើនជាប់ឆ្នោត តែ-មិនដឹងថាត្រូវធ្វើយ៉ាងម៉េច?

រឿងនេះ ស្ត្រីយើងម្នាក់ៗផ្ទាល់ខ្លួនត្រូវតែមានសេចក្ដីក្លាហាននៅក្នុងការសម្រេចចិត្ត ចូលរួមប្រឡូកដោយផ្ទាល់គ្រប់ចលនាសកម្មភាពទាំងឡាយនៅក្នុងសង្គម ដើម្បីឱ្យគេឃើញថា យើងក៏អាចធ្វើបាន យើងក៏មានសមត្ថភាពដូចជាបុរសដែរ ទើបមានឱកាស !





មែនហើយ! ការពិតការងារតើដែលវាបង្រៀនយើង បើខ្ញុំឈរឈ្មោះបោះឆ្នោតលើកនេះ ! តើ អ្នកទាំងអស់គ្នាគាំទ្រខ្ញុំដែរអត់?



គាំទ្រៗៗៗ បេក្ខភាព មីងសុភាព! មួយរយភាគរយ!



ឈប់ៗៗៗៗៗៗ! សូមស្ទាត់ៗៗៗគាំទ្រនោះ ខ្ញុំដឹងថាគាំទ្រ
ហើយ ប៉ុន្តែខ្ញុំ គិតថា វានៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ!



អូ!ល្បង ចង់និយាយថា តើត្រូវបោះឆ្នោតយ៉ាងម៉េចទើបជាប់ស្ត្រី?



ត្រូវហើយ! ខ្ញុំចង់ដឹងឱ្យបានច្បាស់ កុំឱ្យសម្រេចចិត្តទៅវាច្រឡំ!



- រឿងនេះអ្នកមីងសុភាពត្រូវជ្រើសរើស ហើយចូលរួមជាមួយគណបក្សនយោបាយណាមួយ ដែលមីងពេញចិត្ត ។
- ខ្ញុំដឹងថា គណបក្សនយោបាយខ្លះក៏បានលើកផែនការ និងគោលនយោបាយក្នុងការបង្កើនសមាមាត្រស្ត្រី ដែលធានាថា យ៉ាងហោចណាស់ឱ្យមានបេក្ខភាពចំនួន ៣០% ។
- ផែនការ និងគោលនយោបាយនេះនឹងធានាដល់ការដាក់បេក្ខជនជាស្ត្រី និងបេក្ខជនជាបុរសឆ្លាស់គ្នានៅក្នុងបញ្ជីឈ្មោះផ្នែកខាងលើ សំរាប់ការបោះឆ្នោត ។



នែ! បានលោកបងមកអញ្ជើងល្អហើយ ចំពេលដែលពួកខ្ញុំកំពុងត្រូវការ ព្រោះមានចម្ងល់ខ្លះចង់ឱ្យជួយបំភ្លឺ!

# របៀបបោះឆ្នោតឲ្យស្ត្រី



មែនហើយ! មុននឹងបោះឆ្នោត តើត្រូវធ្វើយ៉ាង ម៉េចទើប បោះឆ្នោតឱ្យបានជាប់ស្ត្រីដូចអ្នកមីង សុភាព? ព្រោះគាត់សកម្មណាស់?



- ដំបូងត្រូវពិនិត្យមើលបេក្ខជន បេក្ខនារីឈរឈ្មោះ នៃបញ្ជីគណបក្ស ថាតើមានដាក់បេក្ខជន-បេក្ខនារី ដូចឈ្មោះ អ្នកមីងសុភាព**ឆ្លាស់គ្នា**នៅលេខរៀងខាងលើឬទេ? ព្រោះអ្នកដែលនៅលេខរៀងខាងលើអាចមានលទ្ធភាពជាប់ច្រើន ។
- ចំពោះអ្នកមីងសុភាពយើងទុកចិត្តថា គាត់មិនធ្លាប់ រកស៊ីខុសច្បាប់ បន្លំ ឆបោក ទារប្រាក់ពីប្រជាពលរដ្ឋ ឬប្រព្រឹត្តិអំពើហិង្សាក្នុងគ្រួសារ ឬរំលោភសិទ្ធិអ្នកដទៃ ឬមានបញ្ហាផ្សេងៗទៀតនោះទេ!



រួចចុះយើងទៅមើលបញ្ជីឈ្មោះបេក្ខជននៅឯណា ?



ចាស់! យើងអាចទៅមើលបញ្ជីបេក្ខជនឈរឈ្មោះផ្លូវការ ដែលអាជ្ញាធររៀបចំការបោះឆ្នោតបិទផ្សាយចាប់ពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៨ រហូតដល់ថ្ងៃបោះឆ្នោត គឺថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ខាងមុខ នៅតាមមណ្ឌលបោះឆ្នោតខេត្ត-ក្រុង ជាពិសេស នៅស្នាក់ការគណៈកម្មការខេត្ត-ក្រុងរៀបចំការបោះឆ្នោត និងទីប្រជុំជនធំៗ ពីព្រោះក្នុងសន្លឹកឆ្នោតមិនមានដាក់បង្ហាញបញ្ជីបេក្ខជនឈរឈ្មោះឡើយ ។



អូ! ខ្ញុំយល់ហើយ ឧទាហរណ៍ថា យើងទុកចិត្តមីងសុភាព យើងត្រូវបោះឆ្នោតឱ្យគណបក្សរបស់មីងសុភាពដែលគាត់បានឈរឈ្មោះ! មិនថាអញ្ចឹង លោកបងសម្បត្តិ?



ត្រឹមត្រូវហើយ! ដូច្នេះយើងក៏គួរពិនិត្យផងដែរ អំពីគោលនយោបាយគណបក្សគាត់ ថាតើមាននិន្នាការទៅរកលទ្ធិប្រជាធិបតេយ្យ ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងមានគោលនយោបាយលើកកំពស់សិទ្ធិស្ត្រីឬទេ? ហើយអ្នកដឹកនាំគណបក្សនោះជាអ្នកណា?



ចុះបើបញ្ជីឈ្មោះបោះឆ្នោតរបស់គណបក្សមិនមានដាក់បេក្ខជនបេក្ខនារីឆ្លាស់គ្នានៅលេខរៀងខាងលើ យ៉ាងម៉េចដែរ?



មានន័យថា គេបានបង្កើតឧបសគ្គឱ្យគណបក្សគេដោយខ្លួនឯង ព្រោះគេនឹងបាត់បង់ដៃគូគាំទ្រ និងការអភិវឌ្ឍន៍ដ៏សំខាន់នៅក្នុងសង្គមប្រជាធិបតេយ្យ!



អូ! ខ្ញុំយល់ហើយ! អញ្ចឹងលើកនេះ! យើងទាំងអស់គ្នាត្រូវបោះឆ្នោតឱ្យគណបក្សណាដែលមានដាក់បេក្ខជនជាស្ត្រី-បុរសឆ្លាស់គ្នានៅបញ្ជីឈរឈ្មោះផ្នែកខាងលើ ឬមានបេក្ខនារីភាគច្រើនឈរឈ្មោះក្នុងលំដាប់លេខរៀងលើគេ មានការសន្យាច្បាស់លាស់និងមានគោលនយោបាយលើកស្ទួយសមភាពយេនឌ័រ ។



ពិតមែនហើយ ៗៗៗ

# បោះឆ្នោតគាំទ្រស្ត្រី ដើម្បីឱ្យស្ត្រីមានឱកាសចូលរួមដឹកនាំប្រទេសជាតិរបស់យើង និងដើម្បីភាពរុងរឿងទាំងអស់គ្នា !

សៀវភៅរូបភាពនេះ ដកស្រង់ចេញពីវីដេអូស្ប៊ត (Video Spot) របស់ខុមហ្វ្រែល ស្តីពី "របៀបបោះឆ្នោតជ្រើសរើសស្ត្រី" ។

ប្រសិនបើ អង្គការ សមាគម សហគមន៍ណា មានបំណងចង់យកសៀវភៅនេះទៅ ផ្សព្វផ្សាយ សូមអញ្ជើញទំនាក់ទំនងមកគណៈកម្មាធិការខុមហ្វ្រែល តាមអាសយដ្ឋាន ខាងក្រោមនេះ។


| | | |
|---|---|---|
| រៀបរៀងដោយ : | **ស៊ីនកេត ស៊ីរីលក្ខណ៍** | អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រខុមហ្វ្រែល |
| | **នៅ សម្បត្តិ** | គ្រូបង្គោលខុមហ្វ្រែល |
| ផ្តល់យោបល់ដោយ : | **គល់ បញ្ញា** | នាយកប្រតិបត្តិខុមហ្វ្រែល |

**អាសយដ្ឋានស្នាក់ការកណ្តាលខុមហ្វ្រែល**

ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រ ១១៤៥
ទូរស័ព្ទ ០២៣ ៨៨៤ ១៥០ អ៊ីម៉េល comfrel@online.com.kh
ទូរសារ ០២៣ ៨៨៣ ៧៥០ គេហទំព័រ www.comfrel.org

# យើងត្រូវបោះឆ្នោតឱ្យគណបក្សណា ដែលមានគោលនយោបាយល្អ លើកកំពស់ស្ត្រី គាំទ្រស្ត្រី ដោះស្រាយបញ្ហាស្ត្រី និងបំពេញតាមកិច្ចសន្យារបស់ខ្លួន


គាំទ្រដោយ

NORWEGIAN PEOPLE'S AID

forum syd

n(o)vib OXFAM NETHERLANDS

TROCAIRE Working for a Just World

ឧបត្ថម្ភថវិកាដោយ

From
the People of Japan